# សុន្ទរកថា
# ឯកឧត្តម ងី ច័ន្រ្ទផល
# រដ្ឋលេខាធិការក្រសួងមហាផ្ទៃ
## ក្នុងពិធីបិទសិក្ខាសាលាផ្សព្វផ្សាយអនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
## ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៥

សាលប្រជុំក្រសួងមហាផ្ទៃ (អាគារ S)

- **ឯកឧត្តម រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ....**
- **ឯកឧត្តម លោកជំទាវប្រធានក្រុមប្រឹក្សា និងអភិបាលរាជធានី ខេត្ត**
- **លោក លោកស្រីប្រធានក្រុមប្រឹក្សា និងអភិបាលក្រុង ស្រុក ខណ្ឌ**
- **លោក លោកស្រីតំណាងដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងវិស័យឯកជន**
- **ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីសមាជិក សមាជិកាអង្គសិក្ខាសាលា**

ជាបឋម ក្នុងនាម **សម្តេច ក្រឡាហោម** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប. និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសម្តែងនូវសេចក្តីសោមនស្សរីករាយចំពោះវត្តមានរបស់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីនៅក្នុងសិក្ខាសាលាដ៏មានសារៈសំខាន់នាថ្ងៃនេះ និងសូមវាយតម្លៃខ្ពស់ចំពោះការយកចិត្តទុកដាក់ស្វែងយល់អំពីខ្លឹមសារនៃអនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ព្រមទាំងបានចូលរួមផ្តល់យោបល់ដែលជាធាតុចូលដ៏មានសារៈសំខាន់សម្រាប់ការរៀបចំលិខិតបទដ្ឋានពាក់ព័ន្ធនានាផ្សេងទៀតដើម្បីធានាដល់ការអនុវត្តអនុក្រឹត្យនេះប្រកបដោយប្រសិទ្ធភាពខ្ពស់។

ខ្ញុំក៏សូមថ្លែងអំណរគុណ និងវាយតម្លៃខ្ពស់ចំពោះក្រុមការងារក្រសួងមហាផ្ទៃ ក្រសួងបរិស្ថាន លេខាធិការដ្ឋាន គ.ជ.អ.ប និង**អង្គការមូលនិធិខុនរ៉ាដអាដិនណៅអ៊ែរ** ដែលបានសហការ និងខិតខំប្រឹងប្រែងក្នុងការរៀបចំ និងសម្របសម្រួលសិក្ខាសាលានាថ្ងៃនេះ ឱ្យប្រព្រឹត្តទៅដោយរលូន និងសម្រេចបាននូវលទ្ធផលជាផ្លែផ្កាតាមគោលបំណងដែលបានគ្រោងទុក។

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី!**

នៅក្នុងពិធីបើកសិក្ខាសាលានាពេលព្រឹកមិញ **សម្តេចក្រឡាហោម ស ខេង**

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប បានគូសបញ្ជាក់រួចហើយថា ការវិវត្តយ៉ាងលឿនទាំងផ្នែកសេដ្ឋកិច្ច ផ្នែកហេដ្ឋារចនាសម្ព័ន្ធ និងផ្នែកនគរូបនីយកម្មក្នុងរយៈពេលជាងមួយទសវត្សរ៍កន្លងមកនេះបានធ្វើឱ្យទីក្រុង និងទីប្រជុំជនរបស់យើង កំពុងប្រឈមយ៉ាងធ្ងន់ធ្ងរនូវបញ្ហាពាក់ព័ន្ធនឹងការកកស្ទះសំរាម សំណល់រឹង និងការបំពុលបរិស្ថានដែលកំពុងផ្តល់ផលប៉ះពាល់ជាអវិជ្ជមានដល់សុខភាពសាធារណៈ និងសោភ័ណ្ឌភាពទីក្រុង និងទីប្រជុំជន ហើយបញ្ហាប្រឈមនេះបានក្លាយទៅជារបៀបវារៈដ៏សំខាន់មួយ ដែលរាជរដ្ឋាភិបាលកំពុងផ្តោតការយកចិត្តទុកដាក់ដោះស្រាយ។

ផ្អែកតាមមេរៀនបទពិសោធន៍ល្អៗពីបណ្តាប្រទេសនានា ផ្អែកតាមគោលការណ៍ និងការវិវត្តនៃកម្មវិធីកំណែការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាលបានសម្រេចប្រគល់មុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជននេះទៅឱ្យរដ្ឋបាលរាជធានី រដ្ឋបាលក្រុង រដ្ឋបាលស្រុក ដោយហេតុថា រដ្ឋបាលរាជធានី រដ្ឋបាលក្រុង និងរដ្ឋបាលស្រុក គឺជារដ្ឋបាលថ្នាក់មូលដ្ឋានដែលនៅកៀកជិតប្រជាពលរដ្ឋ និងមានលក្ខណៈសម្បត្តិសមស្របបំផុតក្នុងការទទួលខុសត្រូវលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនប្រកបដោយប្រសិទ្ធភាព។

ខ្ញុំយល់ឃើញថា នេះគឺជាឱកាសដ៏ល្អមួយរបស់រដ្ឋបាលរាជធានី រដ្ឋបាលក្រុង និងរដ្ឋបាលស្រុក ក្នុងការចាប់ផ្តើមអភិវឌ្ឍរដ្ឋបាលរបស់ខ្លួន ឱ្យក្លាយទៅជាស្ថាប័នប្រជាធិបតេយ្យ តំណាងឱ្យសម្លេងប្រជាពលរដ្ឋ និងជាស្ថាប័នដែលមានលទ្ធភាពក្នុងការគ្រប់គ្រង ចាត់ចែងផ្តល់សេវាជូនប្រជាពលរដ្ឋយ៉ាងមានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព ព្រមទាំងមានការចូលរួម និងគោរពស្រឡាញ់ពីសំណាក់ប្រជាពលរដ្ឋ។

ជាការពិតណាស់ ក្នុងរយៈពេលកន្លងមក រដ្ឋបាលក្រុង រដ្ឋបាលស្រុក គឺជារដ្ឋបាលចំណុះឱ្យរដ្ឋបាលខេត្ត ដែលត្រូវបំពេញការងារក្រោមការគ្រប់គ្រងដោយផ្ទាល់ពីរដ្ឋបាលខេត្ត។ នាពេលបច្ចុប្បន្ននេះ ក្រោមក្របខណ្ឌនៃកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រដ្ឋបាលក្រុង រដ្ឋបាលស្រុកបានក្លាយជារដ្ឋបាលមូលដ្ឋានដ៏មានសារៈសំខាន់មួយ ជារដ្ឋបាលដែលស្ថិតក្រោមការដឹកនាំដោយក្រុមប្រឹក្សារបស់ខ្លួន ជារដ្ឋបាលដែលមានស្វ័យភាពក្នុងការធ្វើសេចក្តីសម្រេចចិត្ត មានកញ្ចប់ថវិកា មានប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ មានប្រព័ន្ធកសាងផែនការ និងមាននីតិវិធីបំពេញការងាររបស់ខ្លួន ដែលមិនស្ថិតនៅក្រោមចំណុះ ឬក្រោមសេចក្តីសម្រេចចិត្តរបស់រដ្ឋបាលខេត្តទៀតឡើយ។ នេះជាចំណុចសំខាន់ដែលខ្ញុំចង់គូសបញ្ជាក់ជូនអង្គសិក្ខាសាលានាពេលនេះ ជាពិសេសជូនអស់លោក លោកស្រីដែលជាប្រធានក្រុមប្រឹក្សា និងជាអភិបាលក្រុង ស្រុកទាំងអស់ ត្រូវមានស្មារតីទទួលខុសត្រូវខ្ពស់ និងត្រូវមានគំនិតផ្តួចផ្តើមក្នុងការធ្វើសេចក្តីសម្រេចចិត្តក្នុងការគ្រប់គ្រង ការចាត់ចែងការងារនានា ក្រោម

ស្វ័យភាព និងសិទ្ធិអំណាចរបស់ខ្លួន ដើម្បីធានាដល់ការផ្តល់សេវា និងការអភិវឌ្ឍសេដ្ឋកិច្ចនៅតាមមូលដ្ឋាន សំដៅដោះស្រាយបាននូវបញ្ហាប្រឈមនានា និងឆ្លើយតបបានទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ប្រកបដោយតម្លាភាព គណនេយ្យភាព និងមានប្រសិទ្ធភាពខ្ពស់។

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី!**

សិក្ខាសាលានាថ្ងៃនេះ គឺជាការផ្សព្វផ្សាយអនុក្រឹត្យលេខ១១៣ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ក៏ដូចជាការប្រកាសនូវការប្រគល់មុខងារគ្រប់គ្រងសេវាទីប្រជុំជនដំបូងគេទៅឱ្យរដ្ឋបាលរាជធានី រដ្ឋបាលក្រុង និងរដ្ឋបាលស្រុក។ ជាការពិតណាស់ អនុក្រឹត្យនេះបានកំណត់នូវតួនាទី និងការទទួលខុសរបស់ស្ថាប័នពាក់ព័ន្ធនានា បានកំណត់នូវគោលការណ៍ នីតិវិធី និងវិធានការនានាក្នុងលក្ខណៈជាការផ្តល់ក្របខណ្ឌច្បាប់ និងការតម្រង់ទិសជាយុទ្ធសាស្ត្រគន្លឹះធំៗតែប៉ុណ្ណោះ។

ក្នុងន័យនេះ ដើម្បីធានាជោគជ័យក្នុងការទទួលខុសត្រូវលើការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ឬជាមុខងារផ្តល់សេវាទីប្រជុំជនដ៏មានអត្ថន័យនេះ ខ្ញុំសូមស្នើរដ្ឋបាលរាជធានី រដ្ឋបាលក្រុង និងរដ្ឋបាលស្រុក ត្រូវផ្តោតការយកចិត្តទុកដាក់ក្នុងការផ្តួចផ្តើមគំនិតរៀបចំផែនការ បង្កើតសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងរៀបចំគ្រប់គ្រងប្រតិបត្តិការសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ឱ្យបានស្របតាមស្មារតីនៃអនុក្រឹត្យនេះ ព្រមទាំងឆ្លើយតបយ៉ាងមានប្រសិទ្ធភាពទៅនឹងស្ថានភាពជាក់ស្តែងនៅតាមមូលដ្ឋានរបស់ខ្លួន។

ប្រសិទ្ធភាពនៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនអាចពាក់ព័ន្ធនឹងកត្តាសំខាន់ៗជាច្រើន រួមមានដូចជា កត្តានយោបាយ កត្តាសង្គម កត្តាសេដ្ឋកិច្ច កត្តាបច្ចេកទេស និងការគ្រប់គ្រងការងាររដ្ឋបាល។ អាស្រ័យហេតុនេះ ក្នុងការសម្រេចចិត្តលើជម្រើសនានាសម្រាប់ការគ្រប់គ្រងសេវាសំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន រដ្ឋបាលរាជធានី រដ្ឋបាលក្រុង និងរដ្ឋបាលស្រុកត្រូវពិចារណាទៅលើកត្តាសំខាន់ៗខាងលើ ដើម្បីធានាឱ្យបានថា ការសម្រេចចិត្តផ្នែកនយោបាយនៅក្នុងមូលដ្ឋានរបស់ខ្លួន អាចឆ្លើយតបយ៉ាងមានប្រសិទ្ធភាពទៅនឹងបញ្ហាប្រឈមដែលកំពុងកើតមានឡើងជាក់ស្តែង ការអនុវត្តសេចក្តីចិត្តរបស់ខ្លួនអាចធ្វើឱ្យការយល់ដឹងរបស់ប្រជាពលរដ្ឋកាន់តែមានភាពល្អប្រសើរឡើង និងអាចជំរុញឱ្យមានការចូលលរួមយ៉ាងសកម្ម និងដោយស្ម័គ្រចិត្តពីប្រជាពលរដ្ឋ។ ទន្ទឹមគ្នានេះ ប្រតិបត្តិការផ្នែកបច្ចេកទេសក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនមានលក្ខណៈសមស្រប អាចអនុវត្តបាន និងអាចធានាដល់ការកាត់បន្ថយសំរាម សំណល់រឹងទីប្រជុំជន ព្រមទាំងជំរុញដល់ការប្រើ

ប្រាស់ឡើងវិញ និងការកែច្នៃសំរាម សំណល់រឹងទីប្រជុំជនសម្រាប់បម្រើឱ្យផលប្រយោជន៍ផ្នែកសេដ្ឋកិច្ចផង និងរក្សាបាននូវសុវត្ថិភាពបរិស្ថានផង។ លើសពីនេះ ការគ្រប់គ្រងសេវាសំរាម សំណល់រឹងត្រូវតែមានតម្លាភាព គណនេយ្យភាព និងមានប្រសិទ្ធភាពខ្ពស់។

ជាថ្មីម្តងទៀត ក្នុងនាម គ.ជ.អ.ប ខ្ញុំសូមស្នើដោយទទូចដល់រដ្ឋបាលរាជធានី រដ្ឋបាលក្រុង និងរដ្ឋបាលស្រុកទាំងអស់ត្រូវផ្តោតការយកចិត្តទុកដាក់ប្រកបដោយការទទួលខុសត្រូវខ្ពស់លើការគ្រប់គ្រង និងការចាត់ចែងការងារនេះ ដើម្បីធានាបាននូវសោភ័ណភាព កិច្ចគាំពារសុខភាពសាធារណៈ និងបរិស្ថានស្អាតនៅតាមទីក្រុង និងទីប្រជុំជន ព្រមទាំងដើម្បីផ្តល់មេរៀន និងបទពិសោធន៍ក្នុងការផ្ទេរមុខងារដទៃផ្សេងទៀត ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងបណ្តាឆ្នាំខាងមុខផងដែរ។ ទន្ទឹមនេះដែរ ខ្ញុំក៏សូមស្នើក្រសួង ស្ថាប័ន ក្រុមប្រឹក្សា និងគណៈអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធនានា ត្រូវផ្តោតការយកចិត្តទុកដាក់ក្នុងការអនុវត្តនូវតួនាទី និងភារកិច្ចរបស់ខ្លួនតាមគោលការណ៍ នីតិវិធី និងវិធានការនានាដែលបានកំណត់ក្នុងអនុក្រឹត្យនេះ។

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី!**

មុននឹងបញ្ចប់ ខ្ញុំសូមគូសបញ្ជាក់នូវបញ្ហាសំខាន់មួយផ្សេងទៀត ដើម្បីក្រើនរំលឹកដល់រដ្ឋបាលក្រុង ស្រុកទាំងអស់។ ផ្អែកតាមរបាយការណ៍របស់លេខាធិការដ្ឋាន គ.ជ.អ.ប បានបង្ហាញឱ្យឃើញថា រដ្ឋបាលក្រុង ស្រុកមួយចំនួនបាន និងកំពុងអនុវត្តកិច្ចដំណើរការលទ្ធកម្ម ហើយរដ្ឋបាលក្រុង ស្រុកមួយចំនួនក៏បានឈានទៅអនុវត្តគម្រោងអភិវឌ្ឍរបស់ខ្លួនដោយត្រូវប្រើប្រាស់មូលនិធិក្រុង ស្រុកដែលបានពីការចូលរួមចំណែកពីដៃគូអភិវឌ្ឍន៍ គឺពីស៊ីដា (Sida)។ ពាក់ព័ន្ធនឹងកិច្ចការនេះ ខ្ញុំសូមស្នើឱ្យរដ្ឋបាលក្រុង ស្រុកទាំងអស់ត្រូវរៀបចំចាត់ចែង និងប្រើប្រាស់មូលនិធិទាំងនេះប្រកបដោយតម្លាភាព គណនេយ្យភាព និងតាមនីតិវិធីដែលបានកំណត់។ ក្នុងពេលឆាប់ៗខាងមុខនេះ នឹងមានការចុះធ្វើសវនកម្ម ដោយអជ្ញាធរសវនកម្មជាតិ និងដោយសវនករឯករាជ្យដែលជ្រើសរើសដោយភាគីម្ចាស់ជំនួយ ទៅលើការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់មូលនិធិនេះ។ លទ្ធផលនៃការធ្វើសវនកម្មទាំងនេះ គឺជាល័ក្ខខ័ណ្ឌនៃការសម្រេចចិត្តរបស់ Sida ក្នុងការបន្តការគាំទ្ររបស់ខ្លួនមកលើកម្មវិធីកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា។

ជាទីបញ្ចប់ ក្នុងនាម **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមប្រសិទ្ធិពរជូនឯកឧត្តម លោកជំទាវ អស់លោក លោកស្រីទាំងអស់ទទួលបាននូវពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈកុំបីឃ្លៀងឃ្លាតឡើយ និង**សូមប្រកាសបិទសិក្ខាសាលាផ្សព្វផ្សាយអនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន** ចាប់ពីពេលនេះតទៅ។ **សូមអរគុណ**